# ឯកសារសង្ខេបអំពីដៃគូយុទ្ធសាស្ត្រអនុវត្តន៍កម្មវិធី
# គម្រោងអំពើហិង្សាទាក់ទងនឹងយេនឌ័រ

## សង្ខេបអំពីគម្រោង

មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) និង ការិយាល័យភ្នាក់ងារសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រី (UN Women) រួមគ្នាអនុវត្តគម្រោង «ពង្រឹងកិច្ចការពារ និងការសម្របសម្រួលសេវាអំពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ (GBV) និងការគាំទ្រដល់ខេត្តចំនួនបួន» ដែលជាកម្មវិធីបន្ថែមមានរយៈពេល៥ឆ្នាំក្រោមការគាំទ្រពីកម្មវិធី ACCESS ដំណាក់កាលទី2 (ACCESS 2)។ សកម្មភាពសំខាន់ៗ រួមបញ្ចូលទាំង ការពង្រឹងការគ្រប់គ្រងករណីតាមរយៈប្រព័ន្ធគ្រប់គ្រងករណី ដែលបានសម្របសម្រួលគ្រប់ជ្រុងជ្រោយដែលនឹងត្រូវសាកល្បង និងអនុវត្តក្នុងខេត្តចំនួនពីរ ការធ្វើឱ្យកាន់តែប្រសើរឡើងនូវគុណភាពតាមរយៈការប្រើប្រាស់ម៉ូឌុលទី៥របស់អង្គការសហប្រជាជាតិ នៃឯកសារស្តីពីការសម្របសម្រួលពហុវិស័យ៖ ការសម្របសម្រួល និងអភិបាលកិច្ចនៃការសម្របសម្រួលកញ្ចប់សេវាសារវន្ត (ESP) និងឆ្លើយតបទៅនឹងវប្បធម៌ និងសង្គមជាក់លាក់ ដោយធ្វើការក្នុងភាពជាដៃគូជាមួយក្រសួងកិច្ចការនារី និងដៃគូសំខាន់ៗរបស់ ACCESS 2 ក្នុងការអភិវឌ្ឍគំរូបង្ការដែលនឹងដាក់ឱ្យសាកល្បងក្នុងខេត្តគោលដៅមួយដែលត្រូវបានកំណត់រួចហើយ។ ដើម្បីធ្វើដូចនេះបាន គម្រោងនឹងប្រើប្រាស់ការវិភាគទិន្នន័យដែលមានស្រាប់នៃការអនុវត្តល្អៗ ក៏ដូចជាមេរៀនបទពិសោធន៍ ស្តីពីគំនិតផ្តួចផ្តើមបង្ការក្នុងប្រទេសកម្ពុជាដើម្បីកំណត់គំរូដែលមានប្រសិទ្ធិភាព ក៏ដូចជា ឈរលើមូលដ្ឋានមេរៀនបទពិសោធន៍ពីក្របខណ្ឌ RESPECT Framework និងគោលការណ៍ណែនាំពីមជ្ឈមណ្ឌលអាស៊ីអាគ្នេយ៍សម្រាប់បង្ការអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងរៀនសូត្រពីអ្នកជំនាញដទៃទៀត។

## លទ្ធផលគម្រោង

លទ្ធផលទី១៖ ត្រឹមឆ្នាំ២០២៨ អ្នកផ្តល់សេវាគោលដៅផ្តល់សេវាGBV និងពិការភាពកាន់តែប្រសើរដល់ប្រជាជនកាន់តែច្រើនក្នុងខេត្តគោលដៅ។

លទ្ធផលទី២៖ ត្រឹមឆ្នាំ២០២៨ អភិក្រមគោលនយោបាយ និងផែនការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឆ្លើយតបទៅនឹងអាទិភាពរបស់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងជនមានពិការភាព។

ACCESS 2
Sustainable quality services for all

Australian Aid

| សកម្មភាពសំខាន់ៗ |
| --- |
| **ធាតុចេញទី១៖** កសាងសមត្ថភាពដៃគូយុទ្ធសាស្ត្រ និងរាជរដ្ឋាភិបាលកម្ពុជាក្នុងការសម្របសម្រួលគ្នាទៅវិញទៅមកដើម្បីបណ្តុះបណ្តាលអ្នកផ្តល់សេវាជួរមុខក្នុងខេត្តគោលដៅ៖ សកម្មភាពសំខាន់ៗ រួមមានទាំងការពង្រឹងសមត្ថភាពអ្នកផ្តល់សេវាឆ្លើយតបទៅនឹងGBV ក្នុងវិស័យសុខាភិបាល និងការសម្របសម្រួលជាពហុវិស័យនៅថ្នាក់ជាតិ និងក្រោមជាតិ។<br><br>**ធាតុចេញទី២៖** គោលការណ៍ណែនាំជាតិ និងបទដ្ឋានសម្រាប់ការផ្តល់សេវាត្រូវបានអភិវឌ្ឍ និងផ្សព្វផ្សាយក្នុងខេត្តគោលដៅ៖ សកម្មភាពសំខាន់ៗ រួមមានទាំងការពិនិត្យមើលវឌ្ឍនភាពសមិទ្ធផលពីការគ្រប់គ្រងករណីGBV ការអភិវឌ្ឍន៍ស្តង់ដារនិតិវិធីប្រតិបត្តិ (SOPs) សម្រាប់ការគ្រប់គ្រងករណីដែលផ្តោតការយកចិត្តទុកដាក់លើជនរងគ្រោះ ពង្រឹងសមត្ថភាពដល់ក្រសួងកិច្ចការនារី និងក្រសួងសុខាភិបាលស្តីពីការគ្រប់គ្រងករណី និងការតាមដានត្រួតពិនិត្យគុណភាពសេវាចាំបាច់។<br><br>**ធាតុចេញទី៣៖** ប្រព័ន្ធបញ្ជូនរឹងមាំត្រូវបានបង្កើត និងផ្សព្វផ្សាយដល់អ្នកផ្តល់សេវាដើម្បីលើកកម្ពស់ការយល់ដឹងនិងធានាការប្រើប្រាស់សេវាGBV ការស្តារនីតិសម្បទា និងកិច្ចគាំពារសង្គម៖ សកម្មភាពសំខាន់ៗ រួមមានការវាយតម្លៃយន្តការសម្របសម្រួល និងរៀបចំលក្ខខណ្ឌយោង និង SOPs សម្រាប់លើកកម្ពស់យន្តការសម្របសម្រួលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។<br><br>**ធាតុចេញទី៧៖** អនុវត្តសាកល្បងគំរូថ្មីសម្រាប់ផ្តល់សេវាប្រកបដោយគុណភាព និងត្រូវបានរចនា និងផ្សព្វផ្សាយដល់ដៃគូរបស់ACCESS 2 រួមទាំងគំរូថ្មីសម្រាប់ការទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ៖ សកម្មភាពសំខាន់ៗ រួមមាន ការវាយតម្លៃការងារទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រ ដោយអនុវត្តក្របខ័ណ្ឌ RESPECT និងបង្កើតរួមគ្នានូវគំរូទប់ស្កាត់អំពើហិង្សាទាក់ទងនឹងយេនឌ័រជាចម្បងមួយ សម្រាប់សាកល្បងក្នុងខេត្តគោលដៅមួយ។<br><br>**ធាតុចេញទី៨៖** ការតាមដានត្រួតពិនិត្យ យន្តការព័ត៌មានត្រឡប់ និងការគ្រប់គ្រងទិន្នន័យសម្រាប់សេវាមួយចំនួនត្រូវបានអភិវឌ្ឍ និងសាកល្បងវា៖ សកម្មភាពសំខាន់ៗរួមមាន ការរក្សាទុកប្រព័ន្ធគ្រប់គ្រងទិន្នន័យដែលមានស្រាប់ រៀបចំផ្តល់ជាអនុសាសន៍សម្រាប់ប្រព័ន្ធគ្រប់គ្រងទិន្នន័យដោយឈរលើដំណើរការថ្នាក់ក្រោមជាតិ និងការគាំទ្របច្ចេកទេសដល់ក្រសួងកិច្ចការនារី/ ក្រុមការងារឆ្លើយតបជាពហុវិស័យចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ (TWGG-GBV) ដើម្បីធ្វើឱ្យប្រសើរឡើងនូវការរៀបចំផែនការ និងរបាយការណ៍ប្រចាំឆ្នាំដោយអនុលោមតាមការអនុវត្តផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី (NAPVAW IV)។ |

| |
|---|
| **អ្នកទទួលផល** |
| អ្នកទទួលផលផ្ទាល់រួមមាន ស្ត្រី និងក្មេងស្រីក្នុងខេត្តគោលដៅដែលងាយរងគ្រោះ ឬជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ រួមទាំងជនងាយរងគ្រោះខ្ពស់ និងជនដែលមិនត្រូវបានគេយកចិត្តទុកដាក់ អ្នកផ្តល់សេវាជួរមុខ និង អ្នកទទួលបន្ទុកករណីGBV។<br>អ្នកទទួលផលប្រយោលរួមមាន ប្រជាជនដែលរស់នៅក្នុងសហគមន៍ដែលគម្រោងត្រូវបានអនុវត្ត។ |
| **ភូមិសាស្ត្រគម្រោង** |
| ថ្នាក់ជាតិ(រាជធានីភ្នំពេញ) ខេត្តកំពង់ចាម កំពង់ស្ពឺ រតនគិរី (សហការជាមួយCARE) និង ខេត្តសៀមរាប |
| **ដៃគូអនុវត្តគម្រោង** |
| ក្រសួងកិច្ចការនារី ក្រសួងសុខាភិបាល និងសង្គមស៊ីវិល (ការបង្ការទប់ស្កាត់) និង UNICEF |
| **រយៈពេលគម្រោង** |
| ពីខែមេសា ឆ្នាំ២០២៤ ដល់ ខែមីនា ឆ្នាំ២០២៨ |
| **ព័ត៌មានទំនាក់ទំនង** |


| | |
|---|---|
| មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន (UNFPA) ប្រចាំកម្ពុជា<br>លោកស្រី Sandra Bernklau តំណាងប្រចាំប្រទេស<br>ទូរស័ព្ទ៖( ៨៥៥) ៩២ ៣៣៨ ៥៧៦<br>អ៊ីម៉ែល៖ bernklau@unfpa.org<br><br>ការិយាល័យភ្នាក់ងារសហប្រជាជាតិលើកកម្ពស់សមភាពយេនឌ័រ និងផ្តល់ភាពអង់អាចដល់ស្ត្រី<br>(UN Women Cambodia)<br>លោកស្រី ឃុន សុភា អ្នកសម្របសម្រួលកម្មវិធីប្រចាំប្រទេស<br>ទូរស័ព្ទ៖ (៨៥៥) ៧៨ ៩៧១ ៧២៥<br>អ៊ីម៉ែ៖ sophea.khun@unwomen.org | កម្មវិធី ACCESS 2<br>លោកស្រី ប៊ូ មករា ប្រធានផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ<br>ទូរស័ព្ទ៖ (៨៥៥) ១២ ៦៩៤ ៩៩៤<br>អ៊ីម៉ែល៖ makara.bou@access2cambodia.org |

គម្រោងនេះ ឧបត្ថម្ភដោយរដ្ឋាភិបាលអូស្ត្រាលីតាមរយៈកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី-កម្ពុជាដើម្បីសេវាប្រកបដោយនិរន្តរភាព និងសមធម៌ - ដំណាក់កាលទី២ (ACCESS 2)។

ខែមីនា ឆ្នាំ២០២៤